## ពូជ

ឧទាហរណ៍នៃការបង្កើតពូជ RRIM៧២៨គឺជាលទ្ធផលនៃការបង្កាត់រវាងពូជ GT ១ ដែលជាពូជដំបូងជាមួយ និង ពូជ RRIM ៦២៣ (PB៤៩ x Pil) ដែលជាពូជជំនាន់ទីពីរ ។ពូជ PB ៣១១ គឺជាពូជអ៊ីប្រ៊ីតចុងក្រោយបង្អស់ដែលមានមេបាស្ថិតនៅជំនាន់ទីពីរគឺ RRIM ៦០០ (Tjir ១ x PB ៨៦) និង PB ២៣៥ (PB ៥/៥១ x PB ៥/៧៨)។ ភាគច្រើននៃពូជចុងក្រោយបង្អស់ដូចជាពូជ RRIM៧១២ និង PB២៦០គឺជាសរីរៈចំលងជំនាន់ទីបី ។

## សារៈសំខាន់នៃពូជជាច្រើន

ពូជដែលជារូបធាតុរុក្ខជាតិជាច្រើនបានផ្តល់នូវសារៈសំខាន់យ៉ាងច្រើន ។សារៈសំខាន់ដ៏ធំ បំផុតក្នុងចំណោមសារៈសំខាន់ ទាំងនោះ គឺលក្ខណៈឯកសណ្ឋានភាពដោយភាពខុសគ្នាដោយឡែក១ដែលវា កើតឡើងដោយសារតែសណ្ឋានទូទៅនៃឯកសណ្ឋានភាពសេនេទិច ។រាល់ដើមកៅស៊ូនីមួយ១ នៃពូជកៅស៊ូតែ មួយដែលស្ថិតនៅ ក្រោមលក្ខខណ្ឌដូចគ្នាវាមានបំរែបរួលតិចតួចនូវលក្ខណៈដូចជា ការលូតលាស់ ថាមពល ភាពក្រាស់នៃសំបក ទិន្នផល គុណភាពនៃជ័រកៅស៊ូ ការរស់នៅក្នុងរដូវរងារ ការដុះស្លឹកសារជាថ្មី និងភាព ធន់ទ្រាំទៅនឹង ជំងឺ។ ដើម្បីធ្វើអោយមានលទ្ធភាពទាំងនេះ អ្នករុក្ខវិទូបានអនុវត្តនូវការបណ្តុះបណ្តាលតាម របៀបសេដ្ឋកិច្ច ភាពងាយស្រួលនិងនៅក្នុងលក្ខណៈឯកសណ្ឋានភាពជាច្រើន ។ជាឧទាហរណ៍ដោយសារតែ កំនើនឡើងឯកសណ្ឋាន ភាពមានការរីកដុះដាល ចំនួនដើមឈើដែលត្រូវតែនឹងកាប់ចោលគឺមានចំនួន តិចតួច។ ចាប់តាំងពីពេលនោះមកមានតែចំនួនដើមឈើដែលគេត្រូវការប៉ុណ្ណោះដែលត្រូវបានគេដាំនៅ ក្នុងតំបន់រួម គ្នាមួយ។ ជាលទ្ធផល វាបានកាត់បន្ថយការចំណាយទៅលើការដាំ និង ការថែទាំ។ដោយសារ តែមានលក្ខណៈដូចគ្នានៃគុណភាពជ័រកៅស៊ូវាអាចត្រូវបានគេប្រើប្រាស់សំរាប់គោលបំណងពិសេសជាច្រើន។ ពូជទំនើបដែលផ្តល់ទិន្នផល ខ្ពស់វាមានសក្តានុពលផ្នែកផលិតកម្មច្រើនបើប្រៀបធៀបទៅនិងចំនួនកូនឈើដែលបណ្តុះ ។ ចាប់តាំងពីមានពូជជាច្រើនដែលមានលក្ខណៈពិសេសមកការជ្រើសរើសរូបធាតុ ជាច្រើនសំរាប់តំរូវការពិសេសគឺកើត មានឡើងដែរ។

### ៣.២.១ ការកំនត់អត្តសញ្ញាណពូជ

មានភាពខុសប្លែកគ្នានៃលក្ខណៈរូបសាស្ត្រនៃពូជផ្សេង១គ្នា ។ចំពោះការកំណត់អត្តសញ្ញាណរបស់ពូជជាច្រើននោះ លក្ខណៈនៃភាពខុសប្លែកគ្នាគឺមានសារៈសំខាន់ណាស់( Polhamus ១៩៦២ Mercykutty ១៩៩១)។ទ្រង់ទ្រាយ និង ទំហំកូនកៅស៊ូទើបនឹងដុះព្រមទាំងគំរូក្រឡេក្រឡានៅលើពួកវា គឺបង្ហាញពីភាព

ខុសគ្នា ។កូនកៅស៊ូនៃពូជ RRIM ៦០០ RRII ១១៨ RRII ២០៨ ( Saraswathyamma et al ១៩៨៨ ) PB ៥/៥១ GT ១ និង PB ៣១១គឺ មានទំហំតូចបើប្រៀបធៀបទៅនឹងពូជ RRIM ៦០៥ RRIM ៦២៣ PB ៨៦ GL ១ និង RRII ១០៥ ( Saraswathyamma et al ១៩៨២) ។កូនកៅស៊ូនៃពូជRRII ១១៨លេចចេញក្រឡេក្រឡាច្រើន ។ម៉ាសខ្យល់ច្រើនដែលមានសពាធទាប ដែលនាំយកនូវអាកាសធាតុត្រជាក់និងភ្លៀងកើតនៅក្នុងសសៃនៅលើស្លឹកនិងផ្នែកខាងមុខគឺសំខាន់ណាស់នៅក្នុងពូជ PR ១០៧ (RRIM ១៩៧១b) ។ការលូតលាស់ ទំរង់និងងចេញលក្ខណះនៃការសំដែងចេញនៃដើមកៅស៊ូខ្ចីៗ គឺជាលក្ខណះនៃពូជដ៏ទៃផ្សេងទៀត ។សកម្មភាពនៃការលូតលាស់នៃពូជRRIM ៦០០មានភាពខុសប្លែកគ្នា(RRIM 1970a) ។ចំពោះដើមកៅស៊ូចាស់ទ្រង់ទ្រាយនៃដើមកៅស៊ូរបស់ពូជជាច្រើនគឺមានរាងស៊ីឡាំងប៉ុន្តែដើម ខ្លះកោងដូចជាពូជPB ៦/៩និងដើមទេរចំពោះពូជTjir ១៦(Paardekooper, ១៩៦៥) ។វាយណះភាពនៃសំបកផ្នែកខាងលើគឺជាលក្ខណះពិសេសផ្សេងៗទៀត ។លក្ខណះនៃការបែកមែក សកម្មភាពនៃការលូតលាស់និងកន្លែងប្រសព្វរួមគ្នារវាងដើមនិងមែកគឺមានភាពខុសគ្នានៅក្នុងពូជខុសគ្នា (Paarddekooper, ១៩៦៥) ។ការរីករាលដាលនៃមែកស្រាលៗដែលភ្ជាប់ទៅនឹងដើមមេគឺជាលក្ខណះនៃពូជPB ៥/៥១(RRIM, ១៩៧១c) ។នៅក្នុងពូជជាច្រើនដូចជាTjir ១និងRRIM ៦០៥ដែលមានមែកក្រាស់ធំៗមួយចំនួនចាប់ផ្តើមចេញពីចំនុចដូចគ្នា (RRIM, ១៩៧២) ។ទ្រង់ទ្រាយនៃដំបូលស្លឹកគឺជាលក្ខណះនៃការកំណត់អត្តសញ្ញាណផ្សេងទៀត ។ ដំបូលស្លឹកនៃពូជGT ១គឺមានរាងមូលរឺមានរាងសាជីមូល(RRIM, ១៩៧០b)ហើយRRIM ៦០០គឺមានរាងដូចជាផ្លិត ។ពូជPB ៥/៥១បានបង្ហាញនូវដំបូលស្លឹកមានរាងមូលជាមួយស្លឹកកំរាស់ស្តើងហើយមានចំនួនមិនក្រាស់ទេ ។ ពណ៌ ភាពរលោង វាយណភាព និង ទ្រង់ទ្រាយ ស្លឹកក៏ថែមទាំងបង្ហាញពីភាពខុសគ្នានៃពូជ ។ ស្លឹកគឺមានពណ៌បៃតងចាស់ចំពោះពូជRRII ១០៥មានពណ៌បៃតងលាយខៀវព្រលែតចំពោះពូជGL ១មានពណ៌បៃតងខ្ចីចំពោះពូជRRII ២០៣ និងបៃតងលាយលឿងចំពោះពូជRRIM ៦០០ ។ ស្លឹកកៅស៊ូនៃពូជ RRII ១០៥ GT ១ និង GL ១ស្លឹកគឺ មានភាពរលោង ខណះពេលដែលស្លឹកពូជP ២៦១និងRRIC ១០២មានលក្ខណះស្រអាប់ ។វាយណភាពនៃប្រភេទស្លឹកជាច្រើនគឺមានភាពគ្រើមចំពោះពូជPR ២៦១ទៅជារលោងទន់ចំពោះពូជRRIM ៦០០(DalabaareនិងBenignno ១៩៩៤) ។ ភាពផ្លាស់ប្តូរទ្រង់ទ្រាយនៃស្លឹកតូចៗ នៅផ្នែកកណ្តាលរាងអេលីប ចំពោះពូជRRII ២០៣ និងមានរាងអេលីបបួនជ្រុងចំពោះពូជRRII ១០៥ និងទៅជារាងដូចពងមាន់ចំពោះពូជRRII ៥ ។ ទីតាំងនៃការតំរៀបរបស់ស្លឹកកៅស៊ូថែមទាំង បានបង្ហាញពីភាពខុសគ្នាក្នុងចំណោមពូជផ្សេងជាច្រើន ។ ស្លឹកកៅស៊ូគឺគងលើគ្នាចំពោះពូជRRII ៥

ប្រទាក់ប្រទិនគ្នាចំពោះ ពូជRRIM ៧០៣ និង ស្លឹកបែកពីគ្នាក្នុងពូជRRII ១០៥។ ការកាត់ផ្នែកខាងស្តាំកណ្តាលស្លឹកគឺមានរាងដូចទូកចំពោះ ពូជRRII ១១៨ ទន្ទឹមនឹងពូជRRII១០៥គឺមានរាងសំប៉ែត។ថ្នាក់ៗនៃស្លឹកកៅស៊ូពូជRRIM ៦០០គឺមានរាងមូលដូចកូនបាល់ ផ្ទុយពីពូជRRII ១០៥ដែលមានរាងកោង ខណៈពេលដែលRRII ២០៣និងPR ២៦១គឺមានរាងពាក់ កណ្តាលជុំមូល។ ផ្នែកខាងចុងបំផុតនៃស្លឹកកៅស៊ូគឺមានទំហំនិងទ្រង់ទ្រាយវែងស្រួច មិនដូចគ្នា នៅក្នុងពូជ RRII ៥ ដែលមានរាងវែងស្រួចនៅក្នុងពូជRRII ១០៥ ដែលមានរោមនៅក្នុងពូជRRII ២០៣ និងមាន រាងជាចំណិតនៅក្នុងពូជ RRIM ៦០០។ បន្ទះស្លឹកបានបង្ហាញពីគែមស្លឹកដែលមានរាង ជារលកនៅក្នុងពូជដូច ជាពូជPR ១០៧ (RRIM,១៩៧១b) និងRRII១១៨ ចំនែកឯពូជRRIM ៦០០គឺមានគែមស្លឹកត្រង់។ ពណ៌របស់ជ័រកៅស៊ូអាចថែមទាំងត្រូវបានគេពិចារណា ជាភស្តុតាងមួយដើម្បីកំណត់អត្តសញ្ញាណនៃពូជជាច្រើន។ ជ័រកៅស៊ូនៃពូជRRIM ៦០០,PB ៨៦១និងRRII ២០៨គឺមានពណ៌សខណៈពេលដែលពូជTjir ១ មានពណ៌លឿងព្រលែត។ ជ័រកកនៃពូជជាច្រើនដូចជាពូជRRII២០៣,(Saraswathyamma et,១៩៨៧) មានទំនោរទៅរកការហើរពណ៌ ទៅជាខ្មៅ។

តាមការសង្កេតមើលដោយភ្នែកទៅលើលក្ខណៈរូបសាស្ត្ររបស់ដើមកៅស៊ូគឺ ទំនងជាមានឥទ្ធិពលដោយជំនាញផ្ទាល់ខ្លួននិងលក្ខខណ្ឌបរិស្ថាន។ គំរូអ៊ីសូមែរជាច្រើនគឺ ផ្តល់ភាពជឿជាក់សំរាប់ការកំណត់អត្តសញ្ញាណ ពូជច្រើនជាងលក្ខណៈរូបសាស្ត្រ។ឧបករណ៍សំរាប់កំនត់ចំណាំម៉ូលេគុលគឺ ការដាក់កំណត់នូវការដាច់ចេញនៃប្រវែងប៉ូលីមែរ(RFLP) និង ការពន្យល់ខុសគ្នាៗរបស់DNAទៅតាមដំណាក់កាលលូតលាស់ផ្សេងគ្នារបស់វា(ARAPD)គឺអាចត្រូវបានគេប្រើប្រាស់ សំរាប់ការធ្វើកំណត់អត្តសញ្ញាណកម្មពូជ។

### ២.៣.៣ អក្សរកាត់នៃពូជ

ពូជកៅស៊ូគឺ ត្រូវបានគេដាក់ឈ្មោះក្រោយពីស្ថាប័នផ្សេងៗដែលពួកវាចាប់កំណើតរឺលក្ខខណ្ឌ ដែលវាត្រូវបានគេប្រមូលដោយយោងទៅតាមនិតិវិធីស្តង់ដា។ខាងក្រោមនេះគឺជាច្បាប់ដែលទាក់ទង:

- ពូជដែលស្គាល់តិចតួចមិនគួរសរសេរអក្សរកាត់ទេ
- ចំនុចខណ្ឌគួរតែត្រូវបានគេកំណត់

- ព្យាង្គទីមួយរឺក៏អក្សរពីរដំបូងនៃព្យញ្ជនៈជាច្រើនគួរតែត្រូវបានគេប្រើប្រាស់
- ក្នុងករណីច្រើនជាងមួយពាក្យ មានតែអក្សរដើមប៉ុណ្ណោះដែលត្រូវគេសរសេរជាអក្សរធំ
- ប្រើអក្សរកាត់វែងករណីមានភាពមិនច្បាស់លាស់ឡើង
- ឈ្មោះដែលសរសេរជាអក្សរកាត់គួរសរសេរជាក្រុមមួយ
- គេប្រើប្រាស់លេខអារ៉ាប់ដើម្បីជាសញ្ញចង្អុលប្រាប់
- ដកឃ្លាមួយនៅចន្លោះអក្សរកាត់និងលេខ

ឧទាហរណ៏

| | |
|---|---|
| AVROS | Algemene Verneiging Rubber Planters Oostkust Sumatra, Indonesia |
| BD | Bodjong Datar, Indonesia |
| BPM | Balai Penelitian Perkebuan Meden, Indonesia |
| Ch | Chemara, Malaysia |
| CHM | C.H. Meares, Malaysia |
| Gl | Glenshiel, Malaysia |
| GT | Gongdang  Tapen, Indonesia |
| Hil | Hilcroft, Sri Lanka |
| IAN | Institut Agronomico de Norte, Brazil |
| IRCA | Institut des Recherches sur le Caoutchouc, Ivory Coast |
| IRCI | Institut des Recherches sur le Caoutchouc en Indochine |
| LCB | S’Lands Caoutchouc Bedrijven, Indonesia |
| Lun | Lunderston, Malaysia |

| | |
|---|---|
| Mil | Milakande, Sri Lanka |
| Nab | Nabutenne, Sri Lanka |
| PB | Prang Besar, Malaysia |
| Pil | Pilmoor, Malaysia |
| PR | Proefstation voor Rubber, Indonesia |
| RRIC | Rubber Research Institute of Ceylon (Sri Lanka) |
| RRII | Rubber Research Institute of India |
| RRIM | Rubber Research Institute of Malaysia |
| SCATC | South China Academy of Tropical Crops, China |
| Tjir | Tjirandji, Indonesia |
| Wagga | Wagga, Sri Lanka |
| War | Waringiana, Sri Lanka |

## ៣. ការជ្រើសរើសពូជ

ការដាំកៅស៊ូដែលផ្តល់ផលចំនេញគឺ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹង ការប្រើប្រាស់រូបធាតុរុក្ខជាតិ ។ការសំដែងចេញនៃរូបធាតុរុក្ខជាតិគឺពឹងផ្អែកទៅលើសមាសភាពសេណេទិចនិងអន្តរអំពើជាមួយនឹងកត្តា បរិស្ថាននៅក្នុងតំបន់ដែលបានផ្តល់អោយនិងចាប់ពីមានការផ្លាស់យ៉ាងទូលំទូលាយ ទៅលើតំបន់ ផ្សេងៗជាច្រើន ។ដូច្នេះហើយសំភារះរុក្ខជាតិសំរាប់តំបន់ណាមួយគួរតែ ត្រូវបានជ្រើសរើសយ៉ាងប្រុងប្រយត្ន័បំផុត ។ ខាងក្រោមនេះគឺជាលក្ខណះនៃពូជមួយដែលគួរអោយគេចង់បាន :

- ការលូតលាស់រឹងមាំ
- ទន់ សំបកខាងក្នុងនិងខាងខាងក្រៅក្រាស់
- មានការដុះភ្នែកល្អ

- មានដើមត្រង់ល្អ
- មានជំបូលស្លឹកតូចនិងរលោងជាមួយស្លឹកដែលមានសុខភាពល្អ
- មានភាពធន់ទៅនឹងខ្យល់
- ផ្តល់ទិន្នផលខ្ពស់មុនអាយុកាលជាមួយនឹងការកើនឡើងនូវទិន្នផល
- ដើមនៅតែមានខ្សែវណ្ណល្អទោះបីក្រោយពេលជៀរជ័រ
- ការដុះសំបកថ្មីដែលល្អ
- ជ័រកៅស៊ូដែលផ្តល់នូវគុណភាពល្អ
- ផ្តល់ទិន្នផលល្អនៅពេលរដូវរាំងស្ងួត
- ផ្តល់ផលជាលក្ខណះវិជ្ជមានចំពោះការជៀរជ័រនៅកំពស់ទាប១
- មានភាពធន់ទ្រាំទៅនឹងជំងឺ
- មានភាពធន់ទ្រាំទៅនឹងភាពតឹងតែងរបស់បរិស្ថានដូចជា ភាពត្រជាក់និងភាពរាំងស្ងួត
- មានការកើតឡើងនូវTPDក្នុងក៏រិតទាប

កត្តាបរិស្ថានដែលជះឥទ្ធិពលទៅលើការ សំដែងចេញនៃរូបធាតុរុក្ខជាតិគឺ មានប្រភេទដី និងលក្ខណះរូបសាស្រ្តដី ការកើតមានឡើងនៃជំងឺ ទំរង់នៃភ្លៀងធ្លាក់ ភាពខ្លាំងនៃខ្យល់ ភាពរាំងស្ងួត និង សីតុណ្ហភាព។ ដោយសារតែមានការពិចារណាទៅលើលក្ខណះផ្សេង១ជាច្រើននៃ រូបធាតុរុក្ខជាតិជាច្រើន នៅក្នុងទំនាក់ទំនងទៅនឹងក៏រិតបរិស្ថានិដូច្នេះហើយទើបជាមានការដាក់ក៏រិតនៅក្នុងការជ្រើសរើសរូបធាតុរុក្ខជាតិ។

ពូជជាច្រើនដែលសមស្របទៅនឹងតំបន់ផ្សេង១(តារាងទី១)គ្នាគួរតែគេជ្រើសរើសដោយ ផ្អែកទៅលើមូល ដ្ឋាននៃសក្តានុភាពសេណោទិចរបស់ពួកវាក្នុងការឆ្លើតបទៅនឹងលក្ខណ្ឌបរិស្ថាន។

តារាងទី១ ពូជដែលសមស្របនៅក្រោមបរិស្ថានផ្សេងគ្នា

| តំបន់ | ពូជដែលសមស្រប |
|---|---|
| ជំងឺ Phytophthora ធ្ងន់ធ្ងរ | RRII ១០៥ , PB ២១៧, GT ១, RRIM ៦២៣, RRIM៦២៨, RRIM ៧០១ |
| ការកើតខ្ពស់នូវជំងឺ *Oidium* | RRRIM ៦០០, RRIM ៧០៣, PB ២៦០ |
| ការកើតជំងឺផ្កាឈូកធ្ងន់ធ្ងរ | GT ១, RRII ៥ |
| មានខ្យល់ខ្លាំង | GT ១, PB ២១៧, PB ២៦០, Haiken ១ |
| ត្រជាក់ខ្លាំង | SCATC ៩៣-១១៤, RRII ២០៨ |
| រាំងស្ងួត | PR ២៥៥, PB ២១៧, PB ៣១១, GT ១, RRIM ៦០០, RRII ២០៣ |
| តំបន់មិនកំណត់ | RRII ១០៥, GT ១, PB ២៨/៥៩, PB ២១៧,PB២៥៥ PB ២៦០, RRIM ៦០០, RRII ២០៣ |

ពូជជាច្រើនដែលកំពុងផ្តល់សំរាប់តែតំបន់ពិសេសមួយ បានចង្អុលបង្ហាញថាការសំដែងចេញ របស់វា នៅ ក្នុងតំបន់លំបាកនឹងមានភាពប្រសើរជាងពូជផ្សេងៗដែលប្រើបច្ចុប្បន្ន។

## ៤. ការចុះឈ្មោះពូជជាអន្តរជាតិ

មានអ្នកឯកទេសអន្តរជាតិផ្នែកប្រភេទដំណាំផ្សេងៗ បានធ្វើការចុះឈ្មោះសណ្តានកូនដំណាំថ្មីរី អភិវឌ្ឍន៍ និង ដើម្បីរក្សានូវទិន្នន័យនៃការ ដាំដំណាំកូនកៅស៊ូផ្សេងៗដែលនឹងអាចប្រើប្រាស់បានសំរាប់ការស្រាវជ្រាវនិងកម្មវិធីនៃការធ្វើអោយដំណាំប្រសើរឡើង។

### ៤.១ ការដោះដូរពូជ

ជាទូទៅការដោះដូរពូជជាច្រើនធ្វើឡើងនៅក្នុងចំនោមវិទ្យាស្ថានស្រាវជ្រាវកៅស៊ូផ្សេងៗ រឺបណ្តាប្រទេស ដែលដាំកៅស៊ូគឺស្ថិតនៅក្រោមកិច្ចព្រមព្រៀងទ្វេរភាគី រឺ ផ្អែកលើមូលដ្ឋានពហុភាគី ។ កម្មវិធី ដោះ

ដូរពាណិជ្ជកម្មពហុភាគីដំបូងគឺបានអនុវត្តិនៅឆ្នាំ១៩៥៤(Poardekooper,១៩៥៧)។ មួយម្ភៃឆ្នាំក្រោយមកការដោះដូរ នូវពូជកៅស៊ូជាគជយ័ជាអន្តរជាតិលើកទីពីរនៅក្នុងចំណោមសមាជិកនៃបណ្តាប្រទេសដែល ជាសមាគមនៃផលិតកម្មកៅស៊ូធម្មជាតិ (ANRPC) កើតនៅខែមិថុនា ឆ្នាំ១៩៧៤(Subramaniam ១៩៧៧)។ ស្ថិតក្រោមកម្មវិធីពាណិជ្ជកម្មដោះដូរ ពូជពហុភាគីដែលរៀបចំឡើងដោយ ANRPCគឺផ្អែកទៅ លើការសិក្សាផ្នែកមួយនៃពូជជាច្រើន ដោយអ្នកបង្កាត់រុក្ខជាតិដោយ ពូជយកពីប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ស្រីលង្កា និងថៃដែលពូជបីត្រូវបានគេជ្រើសរើសពីប្រទេសឥណ្ឌា។ពូជនោះគឺ RRII ៥,RRII១១៨, RRII ២០៣។ក្រោមកិច្ចព្រមព្រៀងនៃការដោះដូរទ្វេរភាគី គឺប្រទេសឥណ្ឌាបានទទួល ពូជ ជាច្រើនដែល បាន អភិវឌ្ឍន៍នៅក្នុងប្រទេសចិន ឥណ្ឌូណេស៊ី ឆ្នេរសមុទ្រអ៊ីវ៉ូរី ម៉ាឡេស៊ី ស្រីលង្កា អាមេរិចខាងត្បូង ថៃ (Saraswathyamma et al ១៩៩២)។ពូជដែលបានអភិវឌ្ឍន៍នៅ ប្រទេសឥណ្ឌាគឺត្រូវបានគេផ្តល់ទៅ ប្រទេសចិន ឆ្នេរសមុទ្រអ៊ីវ៉ូរី ម៉ាឡេស៊ី ស្រីលង្កា ថៃ(Saraswathyamma និង Marattukalam ១៩៩៦)។ពូជសរុបមួយចំនួន១២៧បានគេនាមចូលទៅប្រទេស ឥណ្ឌាពីបណ្តាប្រទេសផ្សេងទៀត។

## ៥.ការដាំពូជចំរុះ

### ៥.១ ឧស្សនេះ

ពូជមួយដែលផ្តល់ទិន្នផលខ្ពស់ក្នុងចំនោមពូជកៅស៊ូRRII ជាច្រើនដែលគួរអោយកត់សំគាល់គឺពូជ RRII១០៥។ពូជកៅស៊ូនេះគឺត្រូវបានគេផ្សព្វផ្សាយសំរាប់ការដាំជាលក្ខណះពាណិជ្ជកម្មនៅក្នុងឆ្នាំ១៩៨០ ។ តាមការវិភាគនៃការប្រើប្រាស់ពូជមួយបានបង្ហាញថាអ្នកដាំកៅស៊ូជាច្រើន ជាពិសេសអ្នកមានផ្ទៃដីដាំតិចតួចបានដាំដុះកៅស៊ូប្រមាណជា ៨០ភាគរយនៃផ្ទៃដីទាំងនោះ ហើយបានដាំពូជទាំងនេះចាប់តាំងពីវាត្រូវបានគេផ្សព្វផ្សាយមក។គេបានប៉ាន់ប្រមាណថាស្ទើរតែពាក់កណ្តាលនៃតំបន់កៅស៊ូទាំងអស់នៅប្រទេសឥណ្ឌាគឺគេបានដាំពូជ RRII ១០៥។ឥលូវនេះច្រើនជាង ៩០ភាគរយនៃការដាំកៅស៊ូថ្មីត្រូវបានគេដាំជាមួយនឹងពូជនេះ។ការអនុវត្តនេះបានដឹកនាំឆ្ពោះទៅរកស្ថានភាពនៃការដាំពូជតែមួយក្នុងកំឡុងទសវត្សចុងក្រោយ ។ ប្រសិនបើនិន្នាការនេះនៅតែបន្តវាអាចធ្វើអោយហេតុការណ៍អាក្រក់កើតឡើងដូចជា ការរីករាលដាល នៃជំងឺចំពោះការដាំឯកវប្បកម្មដោយសារតែមូលដ្ឋានសេណេទិចដំណាំតូចចង្អៀត។ទោះបីជាមិនទាន់មានស្ថានភាពភ្ញាក់ផ្អើលកើតឡើងនៅឡើយក៏ដោយក៏វាចាំបាច់ត្រូវការមានវិធានការការពារស្ថានភាពអាក្រក់ដែល នឹង

អាចកើតមានឡើង។ របាយការណ៍ថ្មីជាច្រើនបានបង្ហាញថាករណីជំងឺដែលកើតលើរុក្ខជាតិយកជ័រមិនសូវធ្ងន់ធ្ងរបែរជាធ្ងន់ធ្ងរ ។ តាមរបាយការណ៍បញ្ហាធ្ងន់ធ្ងរថ្មីៗបំផុតគឺ ជំងឺដែលកើតនៅលើស្លឹកឈ្មោះ *Corynespora* ដែលវាមានឥទ្ធិពលអាក្រក់លើពូជកៅស៊ូRRIC១០៣នៅក្នុងប្រទេសស្រីលង្កា ហើយវាបានធ្វើអោយការចាប់អារម្មណ៍ក្នុងការដាំពូជនេះមានការថយចុះ(Liyanageetal,១៩៨៩) ។ពូជRRII ១០៥ ត្រូវបានគេរាយការណ៍ ថាវា បានឆ្លងជំងឺនេះនៅតំបន់Karnatakaក្នុងប្រទេសឥណ្ឌា(Jacob,១៩៩៧) ។

## ៥.២ ការផ្តល់យោបល់ទៅលើការដាំ

ពូជRRIIត្រូវបានគេផ្តល់ជាយោបល់អំពីយុទ្ធសាស្ត្រមួយគឺការជំរុញទឹកចិត្តអោយមានការដាំពូជចំរុះ ។ជាមួយនឹងទស្សនះដើម្បីកាត់បន្ថយទំហំនៃពូជRRII ១០៥នៅក្នុងកម្មវិធីស្តីពីការដាំកៅស៊ូពេលអនាគត នោះក្រុមគណះកម្មការកៅស៊ូ ឥលូវនេះបានផ្តល់ជាយោបល់អោយមានការដាំពូជ ផ្សេងៗជាច្រើន ទៀតដែលត្រូវបានគេជ្រើសរើស។ ពូជជាច្រើនដែលគេរើសគឺផ្អែកទៅលើទិន្នន័យដែលអាចទុកចិត្តបានពីប្រទេសឥណ្ឌា និង ពីបរទេសគឺរួមគ្នានៅក្នុងក្រុមបីផ្សេងគ្នា(តារាងទី ២)ដោយផ្អែកទៅលើដំណាក់កាលនៃការវាយតំលៃ ។ វត្ថុធាតុជាច្រើនដែលរួមមាននៅក្នុងក្រុមទីI គឺត្រូវបានគេអនុញ្ញាតិសំរាប់ការដាំដុះទ្រង់ទ្រាយធំ តែមិនត្រូវអោយដាំលើសពី៥០ភាគរយ នៃផ្ទៃដីដាំដុះទាំងអស់នៅក្នុងតំបន់ណាមួយទេ ។មានតែពូជRRII ១០៥តែប៉ុណ្ណោះដែលត្រូវបានគេដាក់បញ្ចូលនៅក្នុងក្រុមទីIសំរាប់ដែលធ្វើការដាំកៅស៊ូតាមបែបប្រពៃណី ។ចំពោះពូជ RRIM ៦០០និងពូជGT ១គឺកសិករនឹងមិនទទួលយកសំរាប់ការដាំជាទ្រង់ទ្រាយធំនៅក្នុងតំបន់ ដាំដុះកៅស៊ូតាមបែបប្រពីណីទៀតទេដោយសារតែវាងាយទទួលឥទ្ធិពលពីជំងឺក្នុងកំរិតខ្ពស់ហើយ ប្រភេទជំងឺPhytophthoraគឺកើតមានចំពោះពូជRRIM ៦០០ដែលវាថែមទាំងធ្វើអោយទិន្នផលទាប ។រីឯពូជ GT ១គឺងាយទទួលរងជំងឺOidium ។ហេតុដូច្នេះទើបពូជនេះត្រូវបានគេដាក់នៅក្នុងក្រុមទីIIសំរាប់តំបន់ដែល ដាំតាមបែបបុរាណ។ តែទោះជាយ៉ាងណាក៏ដោយក៏ពូជទាំងពីរនេះត្រូវបានគេដាក់នៅក្នុងក្រុមទីIសំរាប់តំបន់ដែលដាំតាមបែបប្រពៃណី(ក្រុមគណះកម្មការកៅស៊ូ,១៩៩៧)

ក្រុមទីIIរួមមានជាច្រើនដែលបានបង្ហាញពីគុណសម្បត្តិរបស់វារយះពេលយូរ និង រយះពេលសមល្មម ។ពួកនេះរួមមានពូជចំនួន ៦ដែលគេអាចដាំពូចចំនួនពារីច្រើនបញ្ចូលគ្នាលើផ្ទៃដីរហូតដល់៥០ភាគរយនៃផ្ទៃដីទាំងអស់នៅក្នុងតំបន់ណាមួយ ។ពូជដែលស្ថិតនៅក្នុងក្រុមទីIIIគឺត្រូវបានគេបែងចែកជាពួក(a),(b),(c),(d) ។ការជ្រើសរើសពូជជាច្រើនពីពួកណាមួយពីពួកទាំងនោះគឺត្រូវបានគេផ្តល់យោបល់អោយធ្វើការដាំ

របូតដល់តែ១៥ភាគរយប៉ុណ្ណោះនោក្នុងតំបន់អាក្រេក្រាត ។ពូចជាច្រើនដែលស្ថិតនៅក្នុងពួក(a) គឺជាពូជដែលផ្តល់ក្តីសង្ឃឹមចំពោះការសំដែងចេញដ៏ល្អនៅក្នុងការដាំទ្រង់ទ្រាយតូចហើយវាសំដែងចេញរយះពេលយូរនៅ ក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេសវីបរទេស។ ចាប់តាំងនោះមករូបធាតុ ទាំងនោះត្រូវបានគេស្នើសុំអោយសប្រើ

សំរាប់តែដាំធ្វើពិសោធន៍តែប៉ុណ្ណោះ ។ពូជដែលនៅក្រោមក្រុម(b)ភាគច្រើនគឺជាការរើសពូជចាស់ៗដែល ធ្វើអោយការសំដែងចេញរបស់វាមិនសូវរីករាលដាលវីក៏ផ្តល់នូវអ្វីដែលជាសេចក្តីប្រាថ្នាក្នុងកំរិតមធ្យម ។នៅតំបន់ដែលពូជទាំងនេះបានសំដែងចេញយ៉ាងល្អនោះ វាមិនមានការដាក់កំណត់នៅក្នុងការដាំដុះដែលគេចង់បាននោះទេ។ ពូជទំនើបជាច្រើនផ្តល់នូវការសំដែងចេញនូវសកម្មភាពល្អមគឺត្រូវបានគេដាក់បញ្ចូលនៅក្នុងក្រុម(c) ។នៅក្នុងក្រុម(d)គឺជាពូជសំរាប់ធ្វើការពិសោធន៍ដ៏ទៃដែលផ្តល់ទិន្នផលវីលក្ខណះបន្ទាប់បន្សំជាច្រើនទៀតដែលគេចង់បាន ។ពួកពូជដែលនៅក្នុងក្រុម(d)នេះថែមទាំងមានពូជជាច្រើនទៀតដែល បានផ្តល់ដោយគណះកម្មការកៅស៊ូ។

តារាងទី ១.ការផ្តល់ជាយោបល់ជាច្រើនចំពោះការដាំពហុពូជ

| ក្រុម | ពូជដែលគេស្នើអោយប្រើ | កំណត់ចំណាំ |
|---|---|---|
| I | RRII ១០៥(ពូជRRIM ៦០០និងGT ១សំរាប់តំបន់ដែល មិនដាំតាមបែបប្រពៃណី) | មិនត្រូវដាំអោយលើសពី៥០ភាគរយនៃនៃផ្ទៃដាំសរុប |
| II | RRIM ៦០០,GT ១,PB ២៨/៥៩,PB ២១៧,RRIM ៧០៣ | ពូជរួមគ្នាបញ្ចូលច្រើនសំរាប់ការដាំរហូតដល់៥០ភាគរយនៃផ្ទៃដីដាំដុះ |
| III | a RRII ៥,RRII ២០៥,PB ២៥៥,PR ២៦១,PB ២៣៥,PB ២៨០,PB ៣១១<br>b Tjir ១,PB ៨៦,GL ១,PR ១០៧,PB ៦១៩,PB ៥១៥១<br>c RRIM ៦០៥,RRIM ៦២៣,RRIM ៦២៨,RRIM ៧០១,RRII ១១៨,RRII | មិនអោយដាំលើសពី ១៥ភាគរយនៅតំបន់អាក្រេក្រាត |

| | | |
|---|---|---|
| | ២០៨ និងគ្រាប់ពហុពូជដែលបានអនុញ្ញាតិ d RRII ៥០,RRII ៥១,RRII ១០៩,RRII ១១៦,RRII ១៧៦,RRII ៣០០,RRII ៣០៨ RRIM ៧១២,RRIM ៧២២,RRIM ៧២៨,PB ២៥៥,PB ៣១២,PB ៣១៤,PB ៣៣០ RRIC ៣៦,RRIC ១០០,RRIC ១០២,RRIC ១០៤,RRIC ១០៥,RRIC ១១០,RRIC ១៣០,Nab ១៧,KRS ២៥,KRS ១២៨,KRS ១៦៣,SCATC ៨៣-១៣,SCATC ៩៣-១១៤,Haiken ១,IRCA ១៨,IRCA ១០៩,IRCA ១៣០,IRCA ២៣០,BPM ២៤ | |

# ៦. ការសំដែងចេញនៃពូជជាច្រើន

## ៦.១ ពូជជនជាតិឥណ្ឌា

### ៦.១.១ ពូជ RRII ១០៥

ពូជRRII ១០៥គឺជាពូជពេញនិយមបំផុតដែលវិវត្តិចេញពីពូជRRII ។មេបានៃពូជនេះគឺ Tjir ១ និងGL ១ ។វាគឺជាពូជរឹងមាំជាមួយថាមពលមធ្យមនិងមានមែកបែកសាខា (លោកNairនិងGeorgeឆ្នាំ ១៩៦៩) ។វាមានដើមខ្ពស់ត្រង់ ។ស្លឹកនិងមែកជាច្រើនបង្កើតជាដំបូលស្លឹកខ្ពស់ពីដីនោះមានលក្ខណះហាប់ល្អ ។ ស្លឹកគឺមានពណ៌បៃតងចាស់ហើយរលោងដោយសារមេបាGL១ឈ្មោល(Nair et al ១៩៧៥) ។ថាមពលនៅកន្លែងចំហានិងកន្លែងចង្អេះនៅលើកន្លែងចាំងសំបកឈើយកជ័រគឺមានកំរិតធម្មតា ។សំបកក្នុងដើមនិងសំបកដែលកើតថ្មីគឺមានកំរាស់ក្រាស់ជាងធម្មតា ។ សំបកផ្ទុកនូវសសៃដឹកនាំជ័រកៅស៊ូដែលរៀបជាជួរជាច្រើន ។

ទិន្នផលឆ្នាំដំបូងនិងឆ្នាំបន្ទាប់ៗមកគឺផ្តល់ទិន្នផលខ្ពស់ក្នុងការដាំពិសោធន៍។ នៅក្នុងទ្រង់ទ្រាយតូចសំរាប់រយះពេល២០ឆ្នាំដំបូងនៃការជ្រៀរជ័រជាមធ្យមនៃការផ្តល់ទិន្នផល ៨១g ក្នុងមួយកន្លែងដែលចាំងសំបកយកជ័រ (Nazeer et al ១៩៨៩)។ នៅក្នុងទ្រង់ទ្រាយធំសំរាប់រយះពេល១៥ឆ្នាំដំបូង វាផ្តល់ទិន្នផលជាមធ្យមគឺ ៦៧g ក្នុងមួយកន្លែងចាំងសំបកយកជ័រ។ តាមការប៉ាន់ស្មាន ទិន្នផលដែលទទួលបានក្នុងមួយឆ្នាំគឺ ទទួលបានចំនួន២៤៩០Kg ក្នុងមួយហិចតា(Nazeer et al ១៩៨៧)។ទិន្នផលមធ្យមនៃផ្នែកពាណិជ្ជកម្មដែលបាន ប៉ាន់ប្រមាណនៅពីរទីតាំងគឺទទួលបាន២៤០០Kg ក្នុងមួយហិចតាក្នុងមួយឆ្នាំរយះពេល១៣ឆ្នាំនៃការជ្រៀរជ័រ។ការជ្រៀរយកជ័រនៅក្រោមប្រពន្ធ័ដែលមានលក្ខណះវិលចុះវិលឡើងជាបន្តបន្ទាប់គឺអនុវត្តិធ្វើការជ្រៀរជ័ររយះពេលបីថ្ងៃម្តងចំពោះពូជនេះ។ទិន្នផលនៅកំឡុងពេលរាំងស្ងួតគឺល្អ។

ពូជនេះគឺងាយទទួលរងខ្ពស់ពីជំងឺផ្កាឈូក។នៅលើពូជនេះក៏ការកើតឡើងនូវTPDដ៏តឹងតែង និងផ្សិតដែលមានលក្ខណះដូចម្សៅកើតល្មមថែមទាំងត្រូវបានគេតាមដាន(Saraswatyamma et al ១៩៧៨)។ ទោះបីជាពូជនេះឆាប់បាក់មែកក៏ដោយក៏វាអាចជៀសផុតពី ការបំផ្លាញនៃខ្យល់ខ្លាំងប្រសិនបើការលូតលាស់មែកគឺត្រូវបានគេធ្វើអោយមានលំនឹង។ការដាក់ជីច្រើនពេករឺការដាក់ជីដោយគ្មាន លំនឹងអាចបណ្តាលអោយ TPDកើតឡើងនិងងាយទទួលរងការបំផ្លាញពីខ្យល់។វាគឺជាពូជមួយដែលធន់នឹងរដូវរងារ។ ពូជនេះបង្ហាញពីកំរិតធន់ទ្រាំល្មមទៅនឹងជំងឺជ្រុះស្លឹកដែលមានលក្ខណះមិនធម្មតាដោយ ធ្វើការប្រើប្រាស់ស្ព្រាយបាញ់សំរាប់ការពារជំងឺ(George et al ១៩៨០)។ថ្មីៗនេះជំងឺដែលមានលក្ខណះជាចំនុចៗកើតនៅលើស្លឹក ដែលបណ្តាលឡើងដោយ *Corynespora* គឺកើតនៅលើដើមដែលចាស់ចំពោះពូជនេះដែលត្រូវបានគេរាយការណ៍ពី Karnataka(RRII ១៩៩៧)។

### ៦.១.២ ពូជRRII ១១៨

ពូជRRII ១១៨គឺជាពូជដែលមានការលូតលាស់យ៉ាងខ្លាំងខ្លា និងមានមេបាជាពូជ Mil ៣/២ និង Hil ២៨។ ពូជនេះមានដើមខ្ពស់ត្រង់មែកដុះល្អនិងមានដំបូលស្លឹកដែលផ្តល់ជាម្លប់នោះល្អស។ ថាមពលនៅកន្លែងចំហគឺខ្ពស់។កំរាស់សំបកគឺល្មមនឹងសំបកដែលផ្ទុកចំនួនជ័រល្មម។ទិន្នផលដំបូង ទទួលបានប្រហែលជាមធ្យមហើយទិន្នផលចេះតែមានការកើនឡើងនៅឆ្នាំបន្តបន្ទាប់។ ទិន្នផលមធ្យមដែលបានពីការដាំកៅស៊ូទ្រង់ទ្រាយតូចកំឡុងពេល៤ឆ្នាំនៃការជ្រៀរជ័រផ្តល់បាន៥០g ក្នុងមួយដើមក្នុងមួយមុខកន្លែងជ្រៀរសំបក។ គេបានប៉ាន់ប្រមាណថាទិន្នផលទទួលបានគឺ១៨៤៥Kg ក្នុងមួយហិចតាក្នុងមួយឆ្នាំ(Nair និង George,១៩៦៩)។

នៅក្នុងការដាំលក្ខណះពាណិជ្ជកម្មពូជនេះបង្ហាញពីការពេញនិយមសំរាប់ធ្វើការដាំដុះ និង ផ្តល់ទិន្នផលជាមធ្យម ១១៦៤Kgក្នុងមួយហិចតាក្នុងមួយឆ្នាំសំរាប់ការជៀរជ័រ១០ឆ្នាំដំបូង។

### ៦.១.៣ ពូជRRII ២០៣

ពូជRRII ២០៣គឺជាពូជដែលផ្តល់ទិន្នផលខ្ពស់ និង មានការលូតលាស់ខ្លាំង។មេបារបស់វាគឺPB ៨៦និងMil ៣/២។ដើមរបស់វាត្រង់ខ្ពស់និងមានសុខភាពល្អ។ដំបូលស្លឹកគឺមានការដុះរាលដាលនិង មានលំនឹងល្អ។វាបង្ហាញថាមពលខ្ពស់នៅកន្លែងចំហ(Saraswathyamma et al ១៩៨០)។ភាពក្រាស់នៃសំបកខាងក្នុងនិងសំបកដែលដុះថ្មីគឺមធ្យម។នៅក្នុងការដាំទ្រង់ទ្រាយធំ ទិន្នផលមធ្យមសំរាប់ការជៀរជ័រ៩ឆ្នាំគឺ ២៥៣៧Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ។ នៅក្នុងតំបន់ដាំកៅស៊ូពាណិជ្ជកម្មនៅក្នុងពីរតំបន់ទិន្នផលជាមធ្យមសំរាប់ការជៀរជ័រ១០ឆ្នាំគឺ ១៨១៨Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ។ ភាពខាប់នៃ ជ័រគឺមានទំនោរទៅរកការហើរ ពណ៌។ទោះជាយ៉ាងណារឿងនេះមិនជះឥទ្ធិពលទៅលើធនធានកៅស៊ូទេ(Saraswathyamma et al១៩៩០) ។ នៅពេលបន្ទះជ័រកៅស៊ូត្រូវបានគេផលិតការហើរពណ៌អាចត្រូវបានគេកំចាត់ចេញ ដោយការប្រើថែមនូវសារ ធាតុសូដ្យូមពីរស៊ុលភីត។ ពូជនេះបង្ហាញថាមានភាពធន់ទៅនឹងគ្រប់ជំងឺទាំងអស់។

### ៦.១.៤ ពូជRRII ២០៨

នេះគឺជាពូជដែលផ្តល់ទិន្នផលច្រើនល្មមនិងមានមេបាជាពូជMil ៣/២និងAVROS ២៥៥។ ពូជនេះមានការបែកមែកល្អ មានដើមត្រង់ Lightsecondariesនិងមានដំបូលស្លឹកមិនសូវក្រាស់។ ពូជនេះគឺងាយទទួលរងនូវការរលួយឫសប៉ុន្តែវាអាចធន់ទ្រាំទៅនឹងជំងឺផ្សេងទៀត(Saraswathyamma et al ១៩៨៩a)។ ទិន្នផលជាមធ្យមដែលទទួលបានពីការដាំទ្រង់ទ្រាយតូចសំរាប់ការជៀរជ័ររយះពេល១៥ឆ្នាំគឺ ៨៥gក្នុងមួយដើមក្នុងមួយកន្លែងជៀរ។ទិន្នផលជាមធ្យមរយះពេល៩ឆ្នាំពីដាំទ្រង់ទ្រាយធំគឺទទួលបាន ២៧៦០Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ។នៅក្នុងតំបន់ដែលធ្វើការវាយតំលៃផ្នែកពាណិជ្ជកម្ម ទិន្នផលជាមធ្យមនៃការជៀរជ័រ ១៧៤៣១Kgក្នុងមួយឆ្នាំក្នុងមួយហិចតា។

### ៦.១.៥ ពូជRRII ៣០០

នេះគឺជាពូជដែលទទួលជោគជយ័មួយផ្សេងទៀតដែលមេបារបស់វាគឺពូជTjir ១និងPB ១០៧។ពូជនេះមានដើមត្រង់និង មានរាងស៊ីឡាំង។វាគឺជាពូជដែលមានមែកទាបៗ ហើយរឹងមាំ។ដំបូលស្លឹកគឺមានចន្លោះមានការបែកមែកល្អនិងមានកំរិតល្មម។ការកើតនូវជំងឺជ្រុះស្លឹកគឺមានកំរិតទាប។ ពូជនេះគឺងាយទទួល រងនូវ

ការរលួយសំបក ។ទិន្នផលជាមធ្យមដែលទទួលបានពីការដាំទ្រង់ទ្រាយតូច សំរាប់រយៈពេលជ្បៀរជ័រ១១ឆ្នាំគឺ ៩៧g ក្នុងមួយដើមក្នុងមួយកន្លែងជ្បៀរជ័រ(Premakumari et al ១៩៨៤) ។

### ៦.១.៦ ពូជRRII៣០៨

ពូជRRII៣០៨គឺជាពូជខ្លាំងដែលមេបារបស់វាគឺជាពូជGL ១និងPB ៦១៥០ ។ពូជនេះមានដើមខ្ពស់ត្រង់ ។ដំបូលស្លឹកគឺក្រាស់បែកមែកសាខានិងមានរាងដូចអំបោស ។ជំងឺផ្សិតនិងជំងឺជ្រុះស្លឹកមិនធម្មតាគឺកើតមានតិចតួច ។ ទិន្នផលជាមធ្យមដែលទទួលបានពីការដាំទ្រង់ទ្រាយតូចក្នុងរយៈពេលជ្បៀរជ័រ១១ឆ្នាំគឺ៧១g ក្នុងមួយដើមក្នុងមួយកន្លែងមុខជ្បៀរ ។តាមការប៉ាន់ស្មានទិន្នផលប្រចាំឆ្នាំគឺ ២៦៤0Kg ក្នុងមួយហិចតា ។ ការកើត ឡើងនូវ TPDគឺខ្ពស់(Premakumari et al ១៩៨៤) ។

### ៦.១.៧ ពូជRRII ៥

នេះគឺជាពូជដំបូងដែលបានជ្រើសពី MalankaraEstate,Thodupuzhaនិងបានធ្វើអោយរីកចំរើនដោយពូជRRII ។វាគឺជាពូជខ្លាំងដែលមានដើមត្រង់ និងដំបូលស្លឹកដែលមានស្លឹកបង្កើតម្លប់ច្រើន ព្រមទាំងមានកំរាស់នៃសំបកក្រាស់ ។វាផ្តល់ទិន្នផលខ្ពស់នៅឆ្នាំដំបូងហើយបន្តការកើនឡើងជាបន្តបន្ទាប់ ។ ទិន្នផលមធ្យមដែលទទួលបានពីការដាំទ្រង់ទ្រាយតូចសំរាប់ការជ្បៀរជ័ររយៈពេល១០ឆ្នាំ គឺ៣២០0Kg ក្នុងមួយហិចតាក្នុងមួយឆ្នាំ ។ទិន្នផលជាមធ្យមដែលទទួលបានពីការដាំទ្រង់ទ្រាយធំសំរាប់ការជ្បៀរជ័រលើសពី ១៦ឆ្នាំគឺ ៧៦,៤២Kg ក្នុងមួយដើមក្នុងមួយកន្លែងជ្បៀរហើយទិន្នផលក្នុងមួយឆ្នាំគឺ ២១៣៨Kg ក្នុងមួយហិចតា (Marattukalam et al ១៩៩២) ។វាងាយទទួលរងទៅនឹងជំងឺ TPD ជំងឺផ្សិត និងជំងឺជ្រុះស្លឹកមិនធម្មតា ។ ទោះបីជាយ៉ាងណាក៏ដោយវាទទួលរងនូវជំងឺផ្កាឈូកនិងការបំផ្លាញពីខ្យល់ក្នុង កិរិតទាប ។

### ៦.១.៨ ពូជអ៊ីប្រ៊ីតថ្មី

ថ្មីៗនេះពូជអ៊ីប្រ៊ីតថ្មីចំនួន១០ដែលជាលទ្ធផលនៃការបង្កាត់រវាងពូជRRII ១០៥និងRRIC ១០០ ត្រូវបានគេកំនត់ថាវាផ្តល់ទិន្នផលខ្ពស់ជាងពូជRRII ១០៥ ។ទិន្នផលវាកើនឡើងជាងពូជRRII ១០៥ពី ៥-៤៩ភាគរយកំឡុងពេល៤ឆ្នាំដំបូងនៃការជ្បៀរជ័រនៅក្នុងការដាំទ្រង់ទ្រាយតូច ។

## ៦.២ ពូជជនជាតិម៉ាឡេស៊ី

### ៦.២.១ ពូជRRII ៦០០

នេះគឺជាពូជបន្ទាប់បន្សំដែលផ្តល់ទិន្នផលខ្ពស់វិវត្តិដោយពូជRRIM និងលូតលាស់យ៉ាងទូលំទូលាយនៅបណ្តាប្រទេសដែលដាំកៅស៊ូទាំងអស់ ។មេបាររបស់វាគឺ Tjir ១និងPB ៨៦ ។ដើមកៅស៊ូនៃពូជនេះគឺខ្ពស់

ត្រង់ឡើងទៅលើមែកដែលមានទំហំធំៗជាច្រើនកើតនៅកន្លែងមុំកែងការបែកមែកមានតិចតួច។ ដំបូលស្លឹកមានទំហំតូចនិងមានរាងជាអំបោស។ ស្លឹកកៅស៊ូគឺស្រាលស្តើងហើយមានពណ៌បៃតងលាយលឿងព្រលែត។ ពន្លកថ្មីដែលទើបនឹងដុះគឺឆាប់បាក់ ហើយខាងចុងមែកគឺមានសភាពទោរកំឡុងពេលដំរយះពេលពីរឆ្នាំដំបូង (RRIM,១៩៧0a,១៩៧១a)។ ថាមពលមុនពេលជៀរជ័រគឺមានកំរិតទាបប៉ុន្តែការបង្កើនខ្សែវណ្ឌនៃការជៀរជ័រគឺល្អ។កំរាស់សំបកខាងក្នុងដើមគឺទាបជាងធម្មតាខណះពេលដែលសំបកកើតថ្មីគឺល្អ។សំបកដែលដុះថ្មីជានិច្ចកាលមានភាពឡើងប៉ោងនៅពីលើកន្លែងជៀរជ័រ។ ពូជនេះបង្ហាញពីការឆាប់ជាសះស្បើយពីការធ្វើអោយមានរបួស។ពូជនេះគឺជាពូជដែលផ្តល់ទិន្នផលខ្ពស់ក្នុងចំនោមពូជជាច្រើនដែលត្រូវបានគេដាំនាពេលបច្ចុប្បន្ន។ នៅក្នុងប្រទេសម៉ាឡេស៊ីទិន្នផលមធ្យមដែលទទួលបាន ពីការដាំកៅស៊ូទ្រង់ទ្រាយធំសំរាប់រយះពេលជៀរជ័រ១៥ឆ្នាំគឺ២១២0១Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ។នៅក្នុងប្រទេសឥណ្ឌា ទិន្នផលមធ្យមដែលទទួលបានពីការដាំកៅស៊ូទ្រង់ទ្រាយធំសំរាប់ការជៀរជ័រ១៦ឆ្នាំដំបូងគឺ ២២00Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ(Marattukalam et al ១៩៩២)និងផ្តល់ទិន្នផលបាន១៣៨៧Kgក្នុងមួយហិចតាក្នុងមួយឆ្នាំចំពោះការដាំកៅស៊ូជាង១០ឆ្នាំ (Joseph និង Haridasn,១៩៩១)។

ពូជនេះសំដែងចេញនូវការកើនឡើងនូវទិន្នផល។ទោះបីជាទិន្នផលដំបូងគឺទទួលបានតែក្នុងកំរិតមធ្យមក៏ដោយ(RRIM,១៩៩២)ក៏ទិន្នផលនៅឆ្នាំបន្ទាប់គឺកើនឡើងក្នុងកំរិតខ្ពស់ណាស់ ។ការធ្លាក់ចុះនៃទិន្នផលនៅរដូវរងារគឺមានកំរិតទាប។ជ័រកៅស៊ូគឺ មានពណ៌សនិងមិនសមស្របដើម្បីធ្វើការបង្ហាប់ចំពោះគ្រឿងយន្តដែលមានភាពលំនឹងទាប។ទោះបីជាវាទទួលរងការបំផ្លាញពីផ្សិត TPD និងការបំផ្លាញពីខ្យល់មានកំរិតទាបក៏ដោយក៏វាទទួលរងការបំផ្លាញដោយជំងឺ*Phytophthora* និងជំងឺផ្កាឈូកក្នុងកំរិតខ្ពស់។វិធានការណ៍ការពារដំមានប្រសិទ្ធិភាពគឺត្រូវការជាចាំបាច់នៅពេលដែលពូជនេះត្រូវបានគេដាំនៅតំបន់ដែលងាយទទួលរងនូវជំងឺ។

### ៦.២.២ ពូជRRIM ៦២៣

ពូជRRIM ៦២៣ គឺជាពូជដែលបានពីការបង្កាត់រវាងពូជPB ៤៩ និងPil B ៨៤។ វាមានដើមខ្ពស់ត្រង់ ក្រាស់ ការបង្កើតនូវការភ្ជាប់មែកជាមុំស្រួចគឺខ្សោយ ។ ផ្នែកកំពូលស្លឹក គឺមានទំហំតូចហើយបានកំនត់ទៅផ្នែកខ្ពស់ជាងគេ។ ដំបូលស្លឹកគឺមានស្លឹកចំនួនច្រើនល្មម ជាមួយនឹងស្លឹកដែលមានទំហំធំៗនិងមានពណ៌បៃតងស្រអាប់។ថាមពលមុនជៀរជ័រគឺខ្ពស់ខ្លាំងនិងការកើនឡើងនូវខ្សែវណ្ឌក្រោយពេលជៀរជ័រគឺល្អ។ ភាពក្រាស់នៃសំបកនៅក្នុងដើមនិងសំបកដែលកើតថ្មីគឺមានកំរិតទាប។ នៅក្នុងប្រទេសឥណ្ឌាទិន្នផលមធ្យមនៃការជៀរជ័រលើសពី១៥ឆ្នាំគឺទទួលបាន១១៧៨Kgក្នុងមួយហិចតាក្នុងមួយឆ្នាំខណះពេល ដែលនៅប្រទេស

ម៉ាឡេស៊ីផ្តល់ទិន្នផល១៦២២Kg ។ពូជនេះធន់ទៅនឹងជំងឺផ្សិត និង ជំងឺដែលបណ្តាលឡើងដោយ *Phytophthora*និងជំងឺពណ៌ផ្កាឈូក ។ពូជនេះមានការទទួលរងនូវជំងឺTPD ។វា ទទួលរងពីការបំផ្លាញពីខ្យល់តិចតួច ។

### ៦.២.៣ ពូជRRIM ៦២៨

វាគឺជាពូជជំនាន់ទីពីរដែលកើតពីការបង្កាត់រវាងពូជTjir ១និងRRIM ៥២៧ ។ពូជនេះមានដើមទេរត្រង់ដែលលេចឡើងនូវភាពបត់បែននៅពេលដើមនៅខ្ចី ។ វាមានមែកធំៗកំពុងលូតលាស់ឆ្ពោះទៅផ្នែកខាងមុខ ។ ទោះបីជាពូជនេះផ្តល់ថាមពលដែលគួរជាទីពេញចិត្តមិនពេលជ្រៀរជ័រក៏ដោយក៏ប៉ុន្តែវានឹងថយទៅវិញនៅពេលគេជ្រៀរជ័ររួច ។ ភាពក្រាស់នៃសំបកនៅក្នុងដើមគឺល្មមហើយសំបកដែលកើតថ្មីគឺមានកំរិតតិច ។នៅប្រទេសឥណ្ឌាទិន្នផលនៃការជ្រៀរជ័រនៃការជ្រៀរជ័រលើសពី១០ឆ្នាំគឺ១០៩៦Kg ក្នុងមួយហិចតាក្នុងមួយឆ្នាំ ។នៅប្រទេសម៉ាឡេស៊ីទិន្នផលមធ្យមនៃការជ្រៀរជ័ររយះពេលលើសពី៧ឆ្នាំគឺ ១០១៩Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ ។វាអាចមានភាពធន់ទ្រាំល្មមទៅនឹងជំងឺ *Phytophthora* ប៉ុន្តែវាងាយទទួលរងនូវជំងឺផ្កាឈូកនិងជំងឺផ្សិត ។ការកើតឡើងនូវ TPDគឺមានកំរិតល្មម ។វាទទួលរងពីការបំផ្លាញពីខ្យល់តិចតួច ។

### ៦.២.៤ ពូជRRIM ៧០១

វាគឺជាពូជដែលកើតឡើងពីមេបា៤៤/៥៥៣ និងRRIM ៥០១ ។ពូជនេះមានដើមត្រង់ មែកមានចំនួនតិចតួចរាងជាមុំស្រួចហើយធំៗ ។ ដំបូលស្លឹកគឺមានរាងជាអំបោសរីរាងពងក្រពើខ្ពស់ហើយក្រាស់ ។ ភាពក្រាស់នៃសំបកខាងក្នុងនិងសំបកដែលកើតថ្មីគឺមានកំរាស់ប្រហែលធម្មតា ។ វាគឺជាពូជដែលមានថាមពលខ្លាំងជាមួយនឹងការកើនឡើងនូវខ្សែវណ្ឌក្រោយពេលជ្រៀរជ័រ ។ ទិន្នផលគឺមានការកើនឡើងជាបន្តបន្ទាប់ ។ នៅប្រទេសម៉ាឡេស៊ីទិន្នផលជាមធ្យមនៃការជ្រៀរជ័រជាង១៥ឆ្នាំគឺ ១៨៤៥Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ (RRIM,១៩៩២) នៅប្រទេសឥណ្ឌាទិន្នផលជាមធ្យមផ្នែកពាណិជ្ជកម្មសំរាប់ការជ្រៀរជ័រ ជាង១០ឆ្នាំគឺ ១១៤០ក្នុងមួយហិចតាក្នុងមួយឆ្នាំ(JosephនិងHaridasan១៩៩១) ។ ពូជនេះគឺងាយទទួលរងនូវជំងឺផ្កាឈូកនិងជំងឺផ្សិតតែទោះជាយ៉ាងណាក៏ដោយវាទទួលរងនូវជំងឺ*Phytophtora*ក្នុងកំរិតទាប ។ មានការកើតឡើងTPDនិងការបំផ្លាញពីខ្យល់ក្នុងកំរិតសមល្មម ។

### ៦.២.៥ពូជRRIM៧០៣

វាជាពូជដែលកើតពីការបង្កាត់រវាងពូជRRIM ៦០០និងRRIM ៥០០ ។ពូជនេះមានដើមត្រង់ឡើងលើហើយរមូល ។ ការបែកមែកគឺយឺតជាមួយនិងការបែកមេកទៅខាងតិចតួច ។ ដំបូលស្លឹកគឺតូចហើយ

ប្រហោងនិងមានរាងពងក្រពើ ។ថាមពលនៅកន្លែងដែលជៀរជ័រចំហគឺមានក៏រិតល្អម ។ សំបកនៅក្នុងដើមនិងសំបកដែលដុះថ្មីគឺក្រាស់ខ្លាំងណាស់ ។នៅប្រទេសម៉ាឡេស៊ីវាផ្តល់ទិន្នផលជាមធ្យមនៃការជៀរជ័រ១៣ឆ្នាំដំបូងគឺ១៧២៦Kgក្នុងមួយឆ្នាំដែលទទួលបានពីការដាំពិសោធន៍ទ្រង់ទ្រាយធំ(RRIM,១៩៨៣) ។ នៅប្រទេសឥណ្ឌាទិន្នផលមធ្យមដែលទទួលបានពីការជៀរជ័រជាង៥ឆ្នាំនៅក្នុងការដាំជាលក្ខណះពាណិជ្ជកម្មគឺផ្តល់ផល១៤២៥Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ ។ទាំងទិន្នផលដំបូងនិងទិន្នផលនៅឆ្នាំបន្តបន្ទាប់គឺខ្ពស់ណាស់ហើយមានក៏រិតថេរ ។ទិន្នផលនៅរដូវក្តៅគឺក្រោមទិន្នផលមធ្យម ។ វាសំដែងចេញនូវភាពធន់តិចតួចទៅនឹងជំងឺផ្កាឈូក ។ ពូជនេះគឺងាយទទួលរងយ៉ាងខ្លាំងពីជំងឺTPD ។ ជំងឺជ្រុះស្លឹកដែលបណ្តាលមកពី*Phytophthora*គឺមានភាពធ្ងន់ធ្ងរនៅប្រទេសឥណ្ឌា ។ គេបានរាយការណ៍ថាការកើតនូវOidiumគឺមានក៏រិតទាប ។ គេបានផ្តល់ពត៌មានមកពីម៉ាឡេស៊ីថា ទិន្នផលមានការធ្លាក់ចុះបន្ទាប់ពីយកជ័របានរយះពេល៨ឆ្នាំ ។

### ៦.២.៦ ពូជRRIM ២៨/៥៩

ពូជនេះគឺជាពូជដំបូងដែលជោគជយ័មួយផ្សេងទៀតជាមួយ នឹង ការផ្តល់ទិន្នផលខ្ពស់ជាពិសេសនៅដើមឆ្នាំនៃការយកជ័រ ។ ថាមពលមុនធ្វើការជៀរជ័រគឺល្អមប៉ុន្តែវាខ្សោយក្រោយពេលជៀរសំបក ។ ភាពក្រាស់នៃសំបកនៅក្នុងដើមគឺ ទាបជាងធម្មតាហើយសបកដែលកើតថ្មីគឺក្រាស់ជាងធម្មតា ។ នៅប្រទេសម៉ាឡេស៊ីកំឡុងពេល១២ឆ្នាំនៃការជៀរជ័រគឺ២២៧៥Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ(RRIM,១៩៩២) ។ ទិន្នផលនៃពាណិជ្ជកម្មនៅប្រទេសឥណ្ឌាសំរាប់ការជៀរជ័រលើសពី១៣ឆ្នាំគឺ ១៤២០Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ (Joseph និង Haridasan,១៩៩០) ។ នៅប្រទេសឥណ្ឌាពូជនេះគឺត្រូវបានគេដាំភាគច្រើននៅក្នុងទីក្រុង Kanyakumari និង ជាពូជដែលផ្តល់ទិន្នផលខ្ពស់បំផុតក្នុងចំនោមពូជដែលត្រូវបានគេណែនាំអោយដាំ ។ ទិន្នផលនៅរដូវក្តៅទទួលបានទាប ។ភាពធន់ទៅនឹងជំងឺ *Phytophthora* ជំងឺផ្កាឈូកជំងឺផ្សិតគឺទាបមែនទែន ។ ពូជនេះគឺងាយទទួលរងខ្ពស់ពីជំងឺTPD ហើយបន្ទាប់ពីនោះមកកំលាំងនៃការចេញជ័រគឺទាប ។

### ៦.២.៧ ពូជRRIM ២១៧

ពូជនេះកើតពីការបង្កាត់រវាងពូជ PB ៥/៥១និងPB ៦/៩ ។ ដើមកៅស៊ូនៃពូជនេះ គឺមានដើមត្រង់មែកស្រាល។មានច្រើន និងមែកធំៗរឹងមាំមានចំនួនតិចតួច ។ ដំបូលស្លឹកគឺមានកំរាស់ក្រាស់ល្អម ។ កំលាំងថាមពលនៅកំឡុងពេលដើមនៅខ្ចី គឺមានក៏រិតល្អមហើយ កើនឡើងក្រោយពេលជៀរសំបក ។ សំបកនៅខាងក្នុងដើមគឺស្តើងប៉ុន្តែកំរាស់នៃសំបកដែលកើតថ្មី គឺមានកំរាស់ល្អម ។ ពូជនេះផ្តល់ទិន្នផលជាមធ្យមគឺ ១៧៨០Kg ក្នុងមួយហិចតាក្នុងមួយឆ្នាំ នៅក្នុងរយះពេល១៣ឆ្នាំនៃ ការដាំកៅស៊ូជាទ្រង់ទ្រាយធំនៅប្រទេសម៉ាឡេស៊ី

(RRIM ១៩៩២) ។ នៅប្រទេសឥណ្ឌាទិន្នផលនៃការដាំជាលក្ខណះពាណិជ្ជកម្មក្នុងរយះពេល១០ឆ្នាំគឺ ១២៥៤Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ(Mercykutty et al១៩៩៥) ។ ទិន្នផលវាកើនឡើងពីទិន្នផលមធ្យម នៅឆ្នាំដំបូងទៅជាទិន្នផលខ្ពស់នៅឆ្នាំបន្តបន្ទាប់ ។ទិន្នផលនៅរដូវក្តៅគឺខ្ពស់មែនទែន ។ជំងឺ*Phytophpra*គឺធ្ងន់ធ្ងរនៅប្រទេសម៉ាឡេស៊ី ប៉ុន្តែវិសាលភាពនៃជំងឺជ្រុះស្លឹកគឺមានកំរិតទាប(Saraswathyamma et al ១៩៨៩b) ។ដោយឡែកជំងឺផ្សិត និងជំងឺផ្កាឈូកក៏មានឥទ្ធិពលទៅលើពូជនេះច្រើនផងដែរ ។

### ៦.២.៨ ពូជPB ២៣៥

ពូជនេះគឺកើតពីការបង្កាត់រវាងមេបាPB ៥/៥១និងPB S/៧៨។ ពូជនេះមានដើមត្រង់ដែលមានប្រពន្ធ័នៃការបែកមែកមានលំនឹងស្រដៀងទៅនឹងពូជPB ៥/៥១ ។ស្លឹកឈើគឺក្រាស់ ។ថាមពលនៅពេលដើមនៅខ្ចីគឺខ្ពស់មែនទែន ។

គេបានរាយការណ៍ពីប្រទេសម៉ាឡេស៊ីថាទោះបីជាពូជនេះវាអាចធន់ទៅនឹង ជំងឺផ្កាឈូក ជំងឺជ្រុះស្លឹកក្នុងកំរិតមធ្យមក៏ដោយក៏កើតឡើងនូវជំងឺ *Phythophthora* មានកំរិតធ្ងន់ធ្ងរនៅប្រទេសឥណ្ឌា។ កំរិតនៃការងាយឆ្លងពីជំងឺផ្សិតគឺខ្ពស់ ។ ជំងឺដើមចេញជ័រដែលបណ្តាលមកពី *Phytophthora* និងដង្កូវស៊ីសំបកគឺកើតនៅតំបន់Kerala.STPនិងការបំផ្លាញពីខ្យល់គឺមានកំរិតធ្ងន់ធ្ងរ ។ ទិន្នផលមធ្យមប្រចាំឆ្នាំនៅប្រទេសឥណ្ឌាសំរាប់ការយកជ័រជាង១០ឆ្នាំដំបូងគឺ១២៦០Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ(Annanma et al,១៩៩០) ។នៅប្រទេសម៉ាឡេស៊ី ទិន្នផលមធ្យមប្រចាំឆ្នាំនៃការជៀរជ័រលើសពី១៥ឆ្នាំដំបូងពីការពិសោធន៍ទ្រង់ទ្រាយធំគឺ២៤៨៥Kgក្នុងមួយហិចតាក្នុងមួយឆ្នាំ ។នៅផ្នែកឥសាន្តនៃប្រទេសឥណ្ឌា ការសំដែងចេញរបស់ពូជនេះគឺល្អ ។

### ៦.២.៩ ពូជPB ២៥៥

ពូជនេះគឺជាពូជដែលកើតនៅប្រទេសម៉ាឡេស៊ី តាមរយះពូជអ៊ីប្រ៊ីតPB ៥/៥១ជាមួយនឹងPB ៣២/៣៦ ។ទិន្នផលមធ្យមនៃការយកជ័រជាង១៣ឆ្នាំដំបូងនៅក្នុងការដាំទ្រង់ទ្រាយធំគឺ២៣១៩Kg ។